MEDIA STATEMENT

UNITED NATIONS HUMAN RIGHTS
OFFICE OF THE HIGH COMMISSIONER

**ការអភិវឌ្ឍសម្រាប់កម្ពុជា ប៉ុន្តែមិនត្រូវមិនគិតគូរពីផលប៉ះពាល់នោះឡើយ - អ្នកជំនាញការ អ.ស.ប អំពាវនាវឲ្យមានការត្រួតពិនិត្យ និងដោះស្រាយសំណងចំពោះផលប៉ះពាល់ពីសម្បទានដី**

ទីក្រុងហ្សឺណែវ (ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៤) - *អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិស្ដីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា លោក សុរិយា ប្រាសាទ ស៊ូប៊ែឌី នៅថ្ងៃនេះ បានអំពាវនាវដល់ក្រុមហ៊ុន ខេ.ឌី.ស៊ី. អន្តរជាតិ (KDC International) ឲ្យបញ្ឈប់នូវគម្រោងអភិវឌ្ឍន៍លើដីដែលមានទំនាស់ នៅខេត្តកំពង់ឆ្នាំង និងបានជម្រុញឲ្យរដ្ឋាភិបាល ធ្វើការត្រួតពិនិត្យឲ្យបានត្រឹមត្រូវលើដីសម្បទាននានា និងផ្ដល់ការដោះស្រាយដោយសមស្របដល់ជនដែលរងផលប៉ះពាល់។*

*លោក ស៊ូប៊ែឌី បានអំពាវនាវផងដែរ ឲ្យមានការស្ងប់ស្ងាត់ និងអត់ធ្មត់ពីសំណាក់អាជ្ញាធរ សមាជិកសហគមន៍ និងកម្មករសំណង់ ពាក់ព័ន្ធនៅក្នុងរឿងទំនាស់ដីធ្លីដ៏រ៉ាំរ៉ៃ និងហិង្សា រវាងក្រុមហ៊ុនខេ.ឌី.ស៊ី. អន្តរជាតិ និងគ្រួសារប្រជាពលរដ្ឋដែលរស់នៅក្នុងឃុំតាជេស៖*

"អស់រយៈពេលជាងដប់ឆ្នាំហើយរហូតមកទល់ពេលនេះ ដែលសហគមន៍មូលដ្ឋានបានជាប់ផុងក្នុងទំនាស់មួយទាក់ទងនឹងដីធ្លីដែលប្រទាញប្រទុងគ្នា និងបណ្ដឹងដែលពួកគេបានដាក់តាមប្រព័ន្ធតុលាការ ប្រឆាំងនឹងអាជ្ញាធរ និងក្រុមហ៊ុន ខេ.ឌី.ស៊ី អន្តរជាតិ ពីការបំភិតបំភ័យ ការប្រើអំពើហិង្សា និងការធ្វើឲ្យបាត់បង់ដីធ្លី ហើយដែលនៅមិនទាន់បានដោះស្រាយនៅឡើយ។
មនុស្សគ្រប់រូបមានសិទ្ធិទទួលបានការជំនុំជម្រះក្ដីមួយប្រកបដោយយុត្តិធម៌ ទាំងក្នុងរឿងក្ដីរដ្ឋប្បវេណី ទាំងក្នុងរឿងក្ដីព្រហ្មទណ្ឌ ហើយការការពារសិទ្ធិមនុស្សប្រកបដោយប្រសិទ្ធភាពនោះ គឺអាស្រ័យទៅលើការអនុវត្តជាក់ស្ដែងក្នុងការទៅប្រើប្រាស់តុលាការ ដែលមានសមត្ថកិច្ច ឯករាជ្យ និងមិនលំអៀង ឬយន្តការដោះស្រាយទំនាស់ផ្សេងៗទៀត ដែលអាច ហើយនឹងផ្ដល់នូវយុត្តិធម៌យ៉ាងត្រឹមត្រូវ។

ទោះជាយ៉ាងណាក៏ដោយ ចំពោះករណីនេះ ក៏ដូចជាករណីទំនាស់ដីធ្លីជាច្រើនទៀត ដែលខ្ញុំបានដឹង ខ្ញុំបានកត់ត្រាអំពី ការផ្ដន្ទាទោសចំពោះសមាជិក និងសកម្មជនសហគមន៍ ទន្ទឹមពេលដែលក្រុមហ៊ុនអាចឈ្លាមយកសិទ្ធិកាន់កាប់លើដីមានទំនាស់ មុនពេលដែលមានសេចក្ដីសម្រេចចេញដោយស្ថាប័នមានសមត្ថកិច្ច ឯករាជ្យ ដែលដោះស្រាយចំពោះការទាមទាររបស់សហគមន៍ ថាដីដែលជួលនោះ

តាមពិតទៅគឺជាកម្មសិទ្ធិរបស់គ្រួសារប្រជាពលរដ្ឋ។

សមាជិកសហគមន៍បាននឹងកំពុងចរចាអំពីសំណងសម្រាប់ដីធ្លី ដែលត្រូវបានដកហូតពីពួកគេរួចហើយ ហើយការចរចានេះស្ថិតក្រោមការគំរាមកំហែងពីការចាប់ខ្លួន។

ខ្ញុំអំពាវនាវឲ្យក្រុមហ៊ុន ខេ.ឌី.ស៊ី. អន្តរជាតិ បញ្ឈប់ភ្លាមនូវការអភិវឌ្ឍលើ ដីដែលមានភាពប្រទាញប្រទុងគ្នានេះ រហូតដល់ការទាមទាររបស់គ្រួសារប្រជាពលរដ្ឋត្រូវបានវាយតម្លៃយ៉ាងត្រឹមត្រូវ ដោយស្ថាប័នឯករាជ្យសមស្របមួយប្រកបដោយយុត្តិធម៌ និងមានតម្លាភាព។ លើសពីនេះទៀត ខ្ញុំអំពាវនាវដល់ភាគីទាំងអស់ឲ្យបង្ហាញភាពអត់ធ្មត់ និងជៀសវាងការប្រឈមមុខដាក់គ្នា និងអំពើហិង្សាបន្ថែមទៀត។

រាជរដ្ឋាភិបាលកម្ពុជា មានកាតព្វកិច្ច ក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិ ក្នុងការការពារ ប្រឆាំងនឹងការរំលោភសិទ្ធិមនុស្ស រួមទាំងការរំលោភបំពានទាំងឡាយ ដែលសហគ្រាសឯកជនជាអ្នកប្រព្រឹត្តិ។ ជាញឹកញាប់បំផុត បណ្ដឹងទៅតុលាការរបស់គ្រួសារប្រជាពលរដ្ឋ ទាមទារកម្មសិទ្ធិលើដីធ្លី ជាមួយម្ចាស់ក្រុមហ៊ុនដែលមានទ្រព្យស្ដុកស្ដម្ភ ត្រូវបានតុលាការច្រានចោល ផ្ទុយទៅវិញបណ្ដឹងទៅតុលាការរបស់ក្រុមហ៊ុនប្រឆាំងនឹងអ្នកភូមិ ត្រូវបានចាត់ការយ៉ាងយកចិត្តទុកដាក់ និងជាលទ្ធផលគឺការផ្ដន្ទាទោសលើអ្នកភូមិ។

បុគ្គលគ្រប់រូបមានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ និងមានសិទ្ធិទទួលបានដោយគ្មានការរើសអើងណាមួយ នូវការការពារស្មើគ្នាចំពោះមុខច្បាប់។ រដ្ឋាភិបាល ត្រូវតែធ្វើការត្រួតពិនិត្យឲ្យបានត្រឹមត្រូវលើសហគ្រាសពាណិជ្ជកម្មទាំងឡាយ ដែលអភិវឌ្ឍលើដីសម្បទាន និងផ្ដល់ការដោះស្រាយចំពោះអន្តរាយដែលបានបង្កឡើង ។

ការបណ្ដេញចេញដោយបង្ខំ មិនអាចបន្តធ្វើឡើងដោយហេតុផលសំអាងថា អ្នកដែលរងការបណ្ដេញចេញ គ្មានឯកសារ ឬប័ណ្ណកម្មសិទ្ធិ ឬក៏កាន់កាប់ដីរដ្ឋ នោះឡើយ។ គ្រួសារប្រជាពលរដ្ឋភាគច្រើនដែលពាក់ព័ន្ធនឹងទំនាស់ដីធ្លី មិនមានសុវត្ថិភាពខាងការកាន់កាប់ដីធ្លី និងគ្មានលទ្ធភាពទៅប្រើប្រាស់នីតិវិធីដោះស្រាយវិវាទដីធ្លីទេ នៅខណៈដែលដីសម្បទាននានា បាននឹងកំពុងបន្តអភិវឌ្ឍលើដីមិនទាន់បានចុះបញ្ជី ឬដីមានទំនាស់។

ល្គឹកណាសិទ្ធិរបស់អ្នកកាន់កាប់ដីធ្លី មិនទាន់ត្រូវបានកំណត់ដោយត្រឹមត្រូវទេ នោះ គ្មានការបណ្ដេញចេញណាមួយធ្វើឡើងដោយស្របច្បាប់ឡើយ។

សិទ្ធិមានលំនៅដ្ឋានសមរម្យ គឺជាសិទ្ធិរបស់ស្ត្រី បុរស យុវវ័យ និងកុមារ ក្នុងការរស់នៅក្នុងលំនៅដ្ឋាន និងសហគមន៍មួយគត់ហ្មត់ និងមានសុវត្ថិភាព ប្រកបដោយសុខសន្តិភាព និងសេចក្ដីថ្លៃថ្នូរ។ ខ្ញុំយល់ច្បាស់ណាស់ថា ប្រជាជនកម្ពុជាគ្រប់រូប ចង់ឃើញការអភិវឌ្ឍ សេដ្ឋកិច្ច ប៉ុន្តែការអភិវឌ្ឍនេះមានការរើសអើង និងគ្មាននិរន្តរភាព ដែលជាញឹកញាប់បំផុតសហគមន៍មូលដ្ឋានមានអារម្មណ៍ថាមានផលប៉ះពាល់អវិជ្ជមានដល់ពួកគេ ដែលតាមពិតទៅ ពួកគាត់គួរតែបានទទួលផលប្រយោជន៍ពីគម្រោងការអភិវឌ្ឍន៍ទាំងនេះ”

## ចប់

*លោកសាស្ត្រាចារ្យ សុរិយា ប្រាសាទ ស៊ូប៊ែឌី ត្រូវបានក្រុមប្រឹក្សាសិទ្ធិមនុស្ស អ.ស.ប តែងតាំងជាអ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ក្នុងខែមិនា ឆ្នាំ២០០៩។ ក្នុងនាមជាអ្នករាយការណ៍ពិសេស លោកជាបុគ្គល ឯករាជ្យ មិនចំណុះរដ្ឋាភិបាល ឬអង្គការណាមួយឡើយ ហើយបំរើការក្នុងសមត្ថភាពបុគ្គលលោកផ្ទាល់។ បច្ចុប្បន្ន លោកជា សាស្ត្រាចារ្យផ្នែកនីតិអន្តរជាតិនៃសាកលវិទ្យាល័យលីដស៍ ចក្រភពអង់គ្លេស និងជាមេធាវីអាជីពមួយរូប នៃគណៈមេធាវី មី ឌឹលថឹមភឹល នៅទីក្រុងឡុង។ លោកជាអនុប្រធានសង្គមអាស៊ីនៃនីតិអន្តរជាតិ និងជាអ្នកនិពន្ធសៀវភៅពាក់ព័ន្ធនឹង គម្រោងសំខាន់ៗ ទស្សនាវដ្តីអាស៊ីនៃច្បាប់អន្តរជាតិ បោះពុម្ពផ្សាយដោយរោងពុម្ពនៃសាកលវិទ្យាល័យខេមប្រ៊ីដជ៍។ សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់គេហទំព័រ*
*http://www.ohchr.org/EN/HRBodies/SP/CountriesMandates/KH/Pages/SRCambodia.aspx*

*អ្នករាយការណ៍ពិសេសរូបនេះ បានដាក់ស្នើអនុសាសន៍របស់គាត់ នៅក្នុងរបាយការណ៍សំខាន់ៗចំនួនប្រាំស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា។ លោក ស៊ូប៊ែឌី នឹងបង្ហាញរបាយការណ៍ សេចក្តីសន្និដ្ឋាន និងអនុសាសន៍ចុងក្រោយបំផុតរបស់លោកទៅក្រុមប្រឹក្សាសិទ្ធិមនុស្ស អ.ស.ប ក្នុងខែកញ្ញា ឆ្នាំ២០១៤។ សូមរកមើលរបាយការណ៍មុនៗរបស់លោកតាមរយៈគេហទំព័រ៖* http://ap.ohchr.org/documents/dpage_e.aspx?m=107

*សិទ្ធិមនុស្ស អប.ស. គេហទំព័រប្រទេស – កម្ពុជា៖*
*http://www.ohchr.org/EN/Countries/AsiaRegion/Pages/KHIndex.aspx*

***សម្រាប់សាកសួរព័ត៌មាន**បន្ថែមអំពីការងាររបស់អ្នករាយការណ៍ពិសេស សូមទាក់ទងមក ៖ នៅទីក្រុងហ្សឺណែវ កញ្ញា អ័លហ្គា ណាកាចូ តាមរយៈទូរស័ព្ទលេខ) +៤១ ២២ ៩២៨ ៩៣៤៨ អ៊ីម៉ែល / onakajo@ohchr.org ឬសរសេរទៅកាន់ srcambodia@ohchr.org*

សំរាប់**ការសាកសួរព័ត៌មាន**ពាក់ព័ន្ធនឹងអ្នកជំនាញការឯករាជ្យដទៃទៀតរបស់ អ ប.ស.៖
សូមទាក់ទងមក សាប៉ៀ ស៊ីលាយ៉ា សិទ្ធិមនុស្ស អ ប.ស.– អង្គភាពព័ត៌មាន តាមរយៈទូរស័ព្ទលេខ (+៤១ ២២ ៩១៧ ៩៣៨៣ អ៊ីម៉េល /xcelaya@ohchr.org)

**សិទ្ធិមនុស្ស អ.ស.ប ស្វែងយល់ពីយើង លើបណ្តាញព័ត៌មានសង្គម៖**
**ហ្វេសប៊ុក៖** https://www.facebook.com/unitednationshumanrights

ទ្វីតធឺ៖ http://twitter.com/UNrightswire
ហ្គោហ្គីល៖ **Google+** gplus.to/unitednationshumanrights
យូធូប៖ http://www.youtube.com/UNOHCHR
បរិយាយសាច់រឿង ៖ http://storify.com/UNrightswire

ផែនកមើលលិបិក្រមសិទ្ធិមនុស្សជាសកល៖ http://uhri.ohchr.org/en